# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំណឹងខាងសាសនា នឹងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកជំពាក់សាសនា: ព្រះគ្រូសុវណ្ណញាណ ស្វរ - ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


| ផ្នែកអក្សរសាស្ត្រ | | ទំព័រ |
|---|---|---|
| លោកអាចារ្យ រស់ - កោ វត្តកែវ | | |
| ព្រះភ្នែង ភ្នំពេញ | វិធីសាងសំឡេង .......... | ៤៤៩ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម | វិធីរក្សារាងកាយ តម្រូវតាមសេចក្ដីត្រូវការ របស់ធម្មជាតិ (តមក) ....... | ៤៦៣ |
| ឃុនសុន្ទរមេធី ញូង - សឿង | ឆកសហស្សរាត្រី ភាគទី ១៤ (តមក)... | ៤៧០ |
| លោកក្រមការ សក់ - ខាត | រឿងព្រេងខ្មែរ "ប្រវត្តិបឹងទុំលែង" .... | ៤៨៣ |

| ផ្នែកសាសនា | | |
|---|---|---|
| ព្រះគ្រូបញ្ញាលំចិត កៅ - សិម | | |
| គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ | យុវចរិយាកថា (តមក) ...... | ៤៨៨ |
| លោកមហា សៅរ៍ - ល័រ | សុភាសិតនឹងការកោភ៩ (តមក) ..... | ៤៩៥ |


ឆ្នាំទី ១៩ — លេខ ៩ ខែកញ្ញា (សេបតេមប្រ៍) ឆ្នាំ ១៩៤៧ — ដំឡៃជាវ ១ ឆ្នាំ ៣៥ រៀល។

# កម្ពុជសុរិយា

RÉGIE DU DÉPÔT LÉGAL

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូសុវណ្ណញាណ ស្វរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

លោកអាចារ្យ រស់-កោ វត្តកែវ ព្រះភ្លើង ភ្នំពេញ — វិធីសាងសំឡេង . . . . . . . . . . . ៤៤៩
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម — វិធីរក្សារាងកាយ តម្រូវតាមសេចក្ដីត្រូវការ របស់ធម្មជាតិ (តមក) . . . . . . ៤៦៣
ឃុនសុន្ទរមេធី ញូង-សឿង — ឯកសហស្សរាត្រី ភាគទី ១៤ (តមក). . . ៤៧០
លោកក្រុមការ សក់-ខាត — រឿងព្រេងខ្មែរ "ប្រវត្តិបឹងទុំសែង" . . . . ៤៨៣

*ផ្នែកសាសនា*

ព្រះគ្រូបញ្ញាល័ចិត កៅ-សឹម គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ — យុវចរិយាកថា (តមក) . . . . . . ៤៧៨
លោកមហា សៅរ៍-សីវ — សុភាសិតនឹងការកោវិទ (តមក) . . . . . ៤៩៥

ឆ្នាំទី ១៩ — លេខ ៩ ខែកញ្ញា (សេបតឹមប៍) ឆ្នាំ ១៩៤៧ — ដំឡៃជាវ ១ ឆ្នាំ ៣៥ រៀល។

# សេចក្ដីជូនដំណឹង

សូម ជំរាប ដល់ អស់ លោក-អ្នក មើល កម្ពុជសុរិយា ទាំងឡាយ សូម បាន ជ្រាប ។

ប្រសិន បើ អស់ លោក បាន មើល ទស្សនាវដ្ដី នេះ ហើយ មាន សេចក្ដី យល់ ទាស់ ឬ យល់ ថា គួរ កែ ប្រែ ដូច ម្ដេច ក្ដី ឬ មួយ អស់ លោក មាន រឿងរ៉ាវ ប្លែកៗ (គតិលោក គតិធម៌) ដែល គួរ នាំ យក មក បុះ ផ្សាយ ដើម្បី ជា សារប្រយោជន៍ ដល់ ជនរួមជាតិ ក្ដី ។ សូម អស់ លោក ថ្លែង យោបល់ ឬ ចាត់ ផ្ញើ រឿងរ៉ាវ ទាំង នោះ ទៅ ពុទ្ធសាសនបណ្ឌិត្យ ហើយ ប្រាប់ បញ្ជាក់ ផង ថា សម្រាប់ បុះ ផ្សាយ ក្នុង កម្ពុជសុរិយា នេះ ។

ពុទ្ធសាសនបណ្ឌិត្យ សូម អរ ព្រះ គុណ អស់ លោក ទុក ជា មុន ។

បណ្ណាធិការ

[illegible]

| | | | |
|---|---|---|---|
| | ពិសោធសំឡេង | | 8.8.65 |
| លោកអាចារ្យ | រស-កោ | (កោវិទបណ្ឌិត) | |
| អាចារ្យបង្រៀននៅសាលា | បាលីរង | វត្តកែវព្រះភ្លើង | ក្រុងភ្នំពេញ |
| | រៀបរៀង | | |

សំឡេង ជាគ្រឿងដៃ (ហត្ថូបករណ៍) ដ៏ប្រសើរបំផុត ទុកជាអាវុធយ៉ាងតូចតែដូចអាវុធដែកក្នុងសមរភូមិ ឬវិសេសជាងគ្រឿងអាវុធទៅទៀត ព្រោះយុទ្ធកណ្ឌទាំងអស់ ប្រើបានតែក្នុងសមរភូមិច្បាំង ឯសំឡេងប្រើបានទូទៅគ្រប់ទីតំបន់ ៗ អាវុធយុទ្ធកណ្ឌ អាចប្រហារបានតែសត្រូវដែលនៅចំពោះមុខ ឬទីណាដែលលម្មប្រហារបាន, ឯអាវុធនៃសំឡេងអាចប្រហារបានមិនចំពោះ ទោះទីណាក៏ដោយ មិនថាឆ្ងាយឬគ្នាគេ អាចប្រើមនុស្សឲ្យទៅស្លាប់បានដោយងាយជាងកាថា ហេតុដល់ទៅអាចធ្វើសត្រូវឲ្យធ្លាក់គ្រឿងអាវុធពីដៃ, ឲ្យបែកសាមគ្គី ឬឲ្យហែកស៊ីសាច់គ្នាឯងវិញក៏សឹងបាន ៗ ហេតុនេះ អ្នកប្រាជ្ញទាំងឡាយទាំងផ្លូវលោកផ្លូវធម៌ទើបប្រកាន់ថា: សំឡេងជាហត្ថូបករណ៍ប្រសើរបំផុត ឬជាយុទ្ធោបករណ៍យ៉ាងវិសេស ប្រើបានគ្រប់ផ្លូវទាំងផ្លូវវិនាសទាំងផ្លូវចំរើន ៗ គ្មានជាគេនាំគ្នាស្វែងរកវិធីសាងសំឡេង ឲ្យទៅជារបស់វិសេសបំផុតដោយបទច្រើនថាក់ច្រើនសង្កាត់ ដូចជានឹងអធិប្បាយត្រួសៗ តទៅនេះ

## ១. ការហាត់ដកដង្ហើមដើម្បីសាងសំឡេង

អ្នកប្រាជ្ញក្នុងវិជ្ជាវោហារៈរបស់អឺរ៉ុប គេអធិប្បាយអំពីចំណោះបញ្ចេញបញ្ចូលខ្យល់ដង្ហើមថា ជាបទរៀនដ៏សំខាន់ដើមដំបូងបង្អស់ របស់អ្នកដែលទើបហាត់ធ្វើជា "វាគ្មី (Orateur)" ឬ "បាឋកៈ (Conférencier)" ផ្សេងៗ ព្រោះតាមប្រក្រតី សំឡេងដែលគេស្រាកស្រាយជាក់ច្បាស់នោះ ត្រូវអាស្រ័យការបញ្ចេញបញ្ចូលខ្យល់យ៉ាងស្រួល ក្នុងខណៈដែលយើងស្រូបអាកាសចូលទៅកាន់សួត ។ អាកាសដែលចូលទៅតាមរន្ធច្រមុះបានដោយស្រួល ត្រូវអាស្រ័យរន្ធច្រមុះដែលមិនតឹងមិនធ្លាសាយ តែគ្រឿងចបសក្តពាំងសម្បុលនេះយើងហាមឃាត់មិនបាន ។ ព្រោះហេតុដូច្នេះ បានជាគេបង្គាប់ឲ្យយើងហាត់បញ្ចេញបញ្ចូលខ្យល់ដង្ហើមគណនាលវាលជាវេលា បើខុគណាជាច្រមុះរបស់យើងតឹងជាប់ហើយក៏ដោយ តែអាកាសដែលចូលទៅកាន់សួតក៏ទឹងទៅជាអាកាសដ៏បរិសុទ្ធ បីបាប់គេក្រសួតឲ្យមានកំឡាំង ជួយសំឡេងឲ្យបានល្អមួយកំណើតទៅទៀត ។

វិធីបញ្ចេញបញ្ចូលខ្យល់ដង្ហើម ដើម្បីប្រយោជន៍ដល់សំឡេង គេឲ្យធ្វើដូច្នេះ :

« ឈរខ្លួនឲ្យត្រង់ ពេនដើមទ្រូងចេញ ឲ្យស្មាទាំង ២ នៅក្នុងលំ-ដាប់ស្មើគ្នា ជើងខាងស្តាំឈានទៅមុខ ជើងខាងឆ្វេងឈប់នៅនឹងកន្លែង

បំពេកចុងជើងទាំង ២ ដើម្បីសណ្ដូកឲ្យជាប់ទីងខ្នងទាំង ៦ ខាង ១ ហើយ ហាត់បញ្ចេញបញ្ចូលខ្យល់ដង្ហើម ដូចតទៅនេះ

ក) បិទមាត់ ដកដង្ហើមចូលឲ្យវែងៗ ព្យាយាមពង្រីកប្រហោងពោះទីងដើមទ្រូងឲ្យពេញបន្ទុក ធ្វើដូច្នេះរាល់តែឃើញថា ខ្យល់ដង្ហើមចូលទៅអស់ហើយ សន្សឹមៗ សន្សៀមៗ បញ្ចេញខ្យល់រាល់តែអស់ ធ្វើត្រឡប់ទៅត្រឡប់មកដូច្នេះឲ្យបានច្រើនៗដង ហើយហាត់ដកដង្ហើមតាមមាត់មើលខ្លះ តាមវិធីដូចគ្នា ។

ខ) ហាមាត់ឲ្យធូលាយ ស្រូវខ្យល់ចូលទុកឲ្យពេញពោះ បិទមាត់ហើយបញ្ចេញខ្យល់ឲ្យចេញមកតាមច្រមុះឲ្យយឺតៗ ឲ្យអស់កម្រិតល្មមទីងយូរបាន ។

គ) យកមេដៃស្ដាំចុកច្រមុះខាងស្ដាំឲ្យជិត ដកដង្ហើមឲ្យជ្រៅតែឲ្យយឺតៗ តាមច្រមុះខាងឆ្វេងរាល់តែឃើញថាអស់ខ្យល់ដង្ហើមហើយ ផ្លាស់មេដៃមកចុកច្រមុះខាងឆ្វេង ហើយដកដង្ហើមចេញសន្សឹមៗ តាមច្រមុះខាងស្ដាំរាល់តែអស់ខ្យល់ ធ្វើត្រឡប់ទៅត្រឡប់មកដូច្នេះ ២-៣ ដង រួចផ្លាស់ធ្វើពីខាងឆ្វេងមុនតាមវិធីដូចគ្នា ។

ឃ) កំណត់ខ្យល់ដង្ហើមក្នុងវេលាដកដង្ហើមចូល រាប់ក្នុងចិត្តឲ្យបាន ៥ ដងទៀតទៅ ល្មមស្រួលទីងវេលាអស់ខ្យល់ ហើយទើបដកដង្ហើមចេញឲ្យយឺតៗ រាប់ក្នុងចិត្តឲ្យបាន ១០-១៥ ដង ។

ង) ការពង្រឹងដុំសាច់ក្នុងស្ពះ ដោយវិធីដកដង្ហើមចូលឲ្យជ្រៅ ប្រមូលខ្យល់ដង្ហើមទុកឲ្យយូរល្មមតែទំនងប្រព្រឹត្តទៅបាន ហើយទើបដកដង្ហើមចេញ; វិធីនេះជាវិធីពង្រឹងដុំសាច់ដើមទ្រូងផង ។

ច) ដកដង្ហើមចេញចូលឲ្យជ្រៅទំនងយឺត ក្នុងរវាងនោះរាប់ដោយសំឡេងសន្ទ្យូ ១ តាំងពី ១ ដល់ ៣០ ។

ឆ) លើកដើមដៃទាំង ២ ឲ្យយ៉ាងត្រង់ឡើងទៅប្រជុំគ្នានៅលើក្បាលឯណោះ ក្នុងខណៈដែលលើកដើមដៃនេះ ឲ្យដកដង្ហើមចូលឲ្យយឺតៗ ព្រមគ្នាទៅផង ព្យាយាមពន្យឺតខ្លួនឲ្យខ្ពស់ល្មមតែនឹងធ្វើឲ្យយឺតទៅបានដោយមិនបាច់បង្អើតជើងឡើង ហើយដកដង្ហើមចេញព្រមទាំងសម្រូតដើមដៃទាំង ២ ចុះ ។

ជ) ក្តាប់ដៃទាំង ២ ឲ្យណែន ដកដង្ហើមចូលព្រមទាំងលើកស្មាទាំង ២ ឡើងចុះឲ្យបាន ៥ ដង ហើយសឹមដកដង្ហើមចេញ ។

ឈ) ដកដង្ហើមចូលហើយដកដង្ហើមចេញយ៉ាងរួសរាន់ ធ្វើយ៉ាងនេះឲ្យបានច្រើន ១ ដង; គ្រប់គ្រា, បើចុះណាជាទីងរហ័សរួសរាន់យ៉ាងណាក៏ដោយ ក៏ត្រូវតែស្រូបខ្យល់ចូលឲ្យបានពេញពោះ; វិធីនេះឲ្យដកដង្ហើមចេញតាមមាត់ខ្លះក៏បាន ។

ញ) ផែកផ្ការឈប់សម្រាកផ្លាស់ទីនៃផ្លូ ដោយប្រាសចាកខ្ចើយ ។

វិធីអប្បការនេះ ជាអនាមយវិទ្យាមួយចំណែក បើនតែបានផលគឺ ការលើតកំឡាំងកងខាងក្នុង ជាវិធីហាត់បញ្ចេញបញ្ចូលខ្យល់ដង្ហើម ដើម្បីជួយទំនុកបម្រុងកងសារសោតសំឡេង ។

មែនពិត វិធីអប្បការនេះ បើយើងគ្រាន់តែសំឡឹងមើល ដោយមិនបានហាត់ធ្វើតាមដែលគេបង្គាប់ ក៏ហាក់ដូចជាមិនគួរជឿថា: នឹងមានផលជួយសារនសំឡេងឲ្យល្អឡើងបានពីត្រង់ណា? តែសេចក្តីពិតនោះ កាលបើល្បងធ្វើមើលគ្រប់ ១ វិធីហើយ ក៏នឹងធ្វើឲ្យការដកដង្ហើមរបស់យើងៈក្រោយពីការឈប់សម្រាក ដើរទៅដោយស្រួល កំឡាំងបានថែមឡើង ធ្វើឲ្យអ្នកហាត់ក្លាយទៅជាមនុស្សជួយកំណត់កិច្ចដែលធ្វើដោយចំ-ពោះមុខ; សេចក្តីអង់អាចកងខាងក្នុង សេចក្តីគិត សេចក្តីចិត បរេនថ្វ ឡើងជាងពីមុន ៗ យ៉ាងណាក៏ដោយ, បើទុកណាជាវិធីខាងដើមតាមដែលគេដកលំទុកនេះនឹងជួយសារសំឡេងឲ្យល្អដោយពិតមិនបាន ក៏គង់តែផលដែលបានកាយដោយចំពោះជាំណែកប្រមុះនឹងបំពង់កៈនោះ បានក្លាយជាអវៈយវៈរឹងប៉ឹង ដើម្បីនឹងបញ្ចេញសំឡេងមកយ៉ាងមានទម្ងន់ជាងកប ។

តាមគម្រារបស់អ្នកបច្ចេកទេសវិយាយថា: បើហាត់បានជាដើមជម្រុំជួប់ៈ ហើយ លំអដែលកន្លកាយនឹងរបះដូងបានខ្លួល ដើម្បីប្រយោជន៍ក្នុងការនិយាយ បានកើតឡើងដល់យើងហើយហើយមិនសួរថែកឹងខ្លួនអស់។

## ២ - ការសាងសំឡេងដោយបំពោះ

កាលបើហាត់វិធីបញ្ចេញបញ្ចូលខ្យល់ដង្ហើមបានស្រួលបួលហើយ យើងចាប់ពន្លឿនការរៀនធ្វើជាក់ទីបុប្ផបង្គៈរបស់យើង ចូលកាន់ថ្នាក់ខ្ពស់តទៅទៀត ។

រយៈតទៅនេះ គេមានវិធីឲ្យរៀនការសាងសំឡេងដោយបំពោះ ។ អ្នកប្រាជ្ញក្នុងផ្លូវសិល្បៈប្រភេទនេះដោយច្រើន បានកាន់យ៉ាងខ្ជាប់ខ្ជួនថា: ការសាងសំឡេងជារបស់សំខាន់មួយក្នុងបណ្តាហត្ថករណ៍ចំណែកផ្សេងៗ របស់អ្នកតន្ត្រីទូទៅ; ដើម្បីនឹងសាង ហើយនឹងរក្សាលំដាប់សំឡេងឲ្យចូលទៅក្នុងប្រភេទដែលល្អជាទីបំផុតល្មមនឹងល្អបាននោះ ខាងដើមត្រូវតែសំដែងការប្រឹងប្រយ័ត្នគោរពចំពោះច្បាប់តម្រិតដែលដំកល់ទុកជាថ្នាក់ៗ មកជាមុនសិន ។

សេចក្តីសុខសេចក្តីស្អាតក្នុងរាងកាយ ជាគ្រឹះខាងដើមដែលសំខាន់មួយទៀតរបស់ការសាងសំឡេង ។

សេចក្តីសុខ-ស្អាតក្នុងទីនេះ គឺសេចក្តីសុខ-ស្អាតក្នុងការងូតទឹក ការស្រូបអាកាស-ដំណេក អាហារ និងគ្រឿងតែងកាយ ។

តាមប្រក្រតី ហាមមិនឲ្យនិយាយខ្លាំង ឬស្រែកពេកទៅ ដោយមិនមានហេតុសំខាន់ និងឲ្យចៀសវាងការនិយាយខ្សឹប ហើយនឹង

សំណើចដោយមិនមានហេតុផលរបស់ខ្លួនចេញ ។ ត្រូវហាត់វិធីដកដង្ហើមឲ្យថ្នមស្ងាត់ម្យ៉ាង, គឺការដកដង្ហើមតាមច្រមុះ ឈប់ការហាមាត់ស្រូបខ្យល់លេង ។ ត្រូវចិញ្ចឹមបបូរមាត់ឲ្យជិតណែន ដើម្បីឲ្យច្រមុះបានមានឱកាសធ្វើការងារបានច្រើនៗ ។

## ៣ – វិធីរក្សាកឹងមាត់

ការដែលផឹកទឹកត្រជាក់ពេក មិនស្រួលដល់ប្រហោងករបស់អ្នកសាច់សំឡេងចុះចម្រើនទំនិយាយ; ក្អកស្រហាក់ ហោចមិនឲ្យចង្អៀតចង្អល់ប្រហោងកដោយមិនមានហេតុសំខាន់ ។ ហួសពីនេះទៅទៀត ការហាត់នៅបានធ្វើឲ្យឃើញប្រយោជន៍យ៉ាងជាក់ច្បាស់ម្យ៉ាង គឺគេហាមមិនឲ្យអ្នកហាត់ផឹកទឹកស្រវឹង ដោយលើកហេតុផលមកតាងថា: គ្រឿងស្រវឹង (ស្រា - កាកៀន - កញ្ឆា - ទឹកថ្នាំជក់ជាដើម សុទ្ធសឹងជារបស់ក្ដៅ) ។ របស់ក្ដៅនែងចូលទៅដុតសរីរាង្គដែលឲ្យស្ងួត ហើយដុតកំដៅសេចក្ដីសប្បាយរបស់សរីរាង្គបំពង់កនោះ ។ សរីរាង្គទាំងនោះក៏អស់សេចក្ដីសប្បាយ ទៅជាញើសញោយ ឬ ខះស្ងួត មិនមានកំឡាំងល្មមនឹងជួយសាច់សំឡេងឲ្យល្អបាន ។ មួយទៀតរបស់គ្រឿងស្រវឹង ធ្វើឲ្យកើតទោសដល់បំពង់កយ៉ាងស្អិតល្អិត សម្បូរពេលនិយាយនឹងឃ្លាតឆ្ងាយចាកវេលាដែក ឬ ដេក ការនិយាយក៏គង់នឹងបានទទួលផលអាក្រក់ជាដរាបទៅ ។ ព្រោះហេតុដែលនេះហើយត្រូវការឲ្យប្រយ័ត្នបំពង់កនេះឯង បានជាមានបញ្ញត្តិ

ឲ្យប្រើទឹកដាំនឹងអំបិលម្សៅប៊ូរ លាងលាក់បំពង់ករាល់ព្រឹកល្ងាចព្រមទាំងវេលាមុននឹងចូលដេក ។ វិធីរក្សាកនិងមាត់តាមវិធីអនាម័យដូច្នេះ ឃើញច្បាស់បានថាៈ ដើម្បីធ្វើកនិងមាត់ឲ្យជាឧបករណ៍ ប្រយោជន៍ជួយឧបត្ថម្ភក្នុងការសាងសំឡេង ដើម្បីជាអាវុធក្នុងពេលត្រូវការនិយាយនុះឯង ។

ដោយច្រើនពួកអ្នកទូទៅ មានរបស់ធ្វើឲ្យគិតផ្ចង់មួយកន្លែង គឺគេបានធ្វើបន្តការហាត់តាមវិធីកំណត់ ៗ ផ្សេងពីគ ពួកអ្នកទីត្រូវបស្រុកតែមិនបដិសេធធ្វើរបស់ខ្លួនថាៈ ខ្លួនបានមានគោលហាត់ក្នុងការនិយាយ ឲ្យប្រព្រឹត្តទៅតាមសេចក្តីសាបរបស់ខ្លួនឯងជាដរាប ៗ តែថាដែលធ្វើតាមសេចក្តីសាបដោយជឿខ្លួនឯងនោះ យើងច្រើនតែធ្វើទៅតាមសេចក្តីពេញចិត្តនឹងនឹកឃើញ គឺដូចកាលយើងនឹងបានចាប់គោលក្នុងការហាត់និយាយរបស់យើងដោយល្អនោះក៏ទេ យើងមានគោលខ្លាក់ម្យ៉ាង ៗ សឹងដោយច្រើនតែជាគោលរបស់យើងឯង ៗ

គោលហាត់ក្នុងខាងដើម តាមវិធីអនាម័យដូចបានពោលមកហើយ យើងសូមផ្ដាំលោក-អ្នកដោយសេចក្តីទុកក្នុងចិត្តថាៈ សូមកុំឲ្យលោក-អ្នកធុញទ្រាន់មុនការប្រាថ្នាព្យាយាមធ្វើជាលំដាប់ ៗ យើងហ៊ានសន្យាយ៉ាងជាក់ស្ដែងថាៈ កាលបើបានធ្វើតាមវិធីហាត់ក្នុងសៀវភៅនេះ ដោយសព្វគ្រប់ហើយ លោក-អ្នកមុខជានឹងបានផលយ៉ាងវិសេសមហាស្ចារ្យ

ដោយលោក-អ្នកមិនដឹងខ្លួន ។ សេចក្ដីសម្រេចរបស់លោក-អ្នក បើទុកណាជាយឺតយូរ តែក៏ទីងជាសេចក្ដីសម្រេចឈានទៅមុខហើយមាំមួនផង !!!

## ៤ – ការបញ្ចេញសំឡេងឲ្យច្បាស់លាស់

អ្នកប្រាជ្ញស្ទាត់ជំនាញក្នុងការមើលលក្ខណៈរបស់មនុស្ស គេមានវិធីម្យ៉ាង សម្រាប់ចាប់យកមកជាវិធីកំបាំងក្នុងការទាយ គឺការស្ដាប់ទឹកសំឡេងរបស់អ្នកដែលគេត្រូវការទំនាយ ។ ទឹកសំឡេងដែលគេចាប់យកមកជាហេតុបករណ៍ក្នុងការមើលលក្ខណៈនេះ មិនមែនចាប់យកចំពោះតែក្នុងវេលានិយាយនោះទេ សូម្បីតែក្នុងការអាន ក៏ជាជំនួយដ៏សំខាន់មួយផ្សេងដែលគេត្រូវការ ។

សំឡេងជាគ្រឿងប្រាប់លក្ខណៈក្នុងកាយបុគ្គល, សំឡេងជាគ្រឿងសឲ្យឃើញសេចក្ដីទម្រន់-សេចក្ដីម៉ឺងម៉ាត់-សេចក្ដីសុភាពទន់លំទោន-សេចក្ដីរញ្ញា-សេចក្ដីនឹងនួន ទីងអនាគតរបស់អ្នកបញ្ចេញសំឡេងរបស់ខ្លួនចេញមកបានជាដរាប ។ រួមសេចក្ដីថា សំឡេងជាផែនទីមួយផ្ទាំង ដែលអាចចង្អុលប្រាប់តំណែងរបស់អ្នកជាម្ចាស់សំឡេងបានថា គេនឹងនៅក្នុងលំដាប់ណា? - ទីណា?

អ្នកតំណាងក្រសួង ឬ តំណាងប្រទេស វេលាដែលត្រូវនិយាយការឲ្យពួកសមាជិក ក្នុងវេទសភាទាំងអស់យល់ឃើញព្រមតាមមតិរបស់ខ្លួន

នោះ ត្រូវប្រើ «សំឡេង» របស់ខ្លួនជាដាវយ៉ាងមុត កាប់ផ្ដាសេចក្ដីយល់របស់អ្នកម្នាក់ឲ្យរលំដួលយល់ព្រមតាមខ្លួននិយាយ ដែលជាការបានប្រយោជន៍ ហើយឲ្យមានប្រៀបដល់ហោចណាស់ ឬប្រទេសរបស់ខ្លួន ។

ដូចទាហានដែលគាប់គ្រប់គ្រងពលចំបាំងរបស់ខ្លួន, គ្រូអ្នកធ្វើការបង្រៀនសិស្សគណរបស់គេ, បព្វជិតអ្នកទេសនាប្រដៅប្រជាជន, នាយកពួកសម្ព័ន្ធដែលត្រូវការបញ្ចុះបញ្ចូលឲ្យមនុស្សធ្វើការដើម្បីខ្លួនកម្មករកំពុងបោះបង់ពេលការទៅនោះ ឲ្យត្រឡប់ចូលមកធ្វើការវិញបាន អ្នកសាក្ខីដែលអធិប្បាយរឿងក្ដីចាប់ចិត្តម្នាក់ទោសទៅលើគូក្ដីម្ខាង ឬ ដោះសារក្ដីក្ដីរបស់ខ្លួន; គង់ឃើញសេចក្ដីសំខាន់របស់ «សំឡេង» ច្រើនជាន់ប្រាកដដែរ ។

៥

ដំណើរដែលនឹងនាំទៅកាន់ភាពជាអ្នកប្តូបតិភះយ៉ាងច្បាស់ក្រឡែតគង់ពុំមាន "សំឡេង" ជាការមួយយ៉ាងសំខាន់ ប្រហែលនឹងសេចក្ដីសំខាន់របស់កាំបិតដែកក្នុងយុទ្ធកម្ម ។

តាំងការនិយាយនិងការអាន បើទុកណាជាត្រូវធ្វើដោយវិធីផ្សេងគ្នាក្នុងភាពមិនដូចគ្នា តែទាំង ២ យ៉ាងត្រូវការ "សេចក្ដីជាក់ច្បាស់" ប្រហែល ៗ គ្នា ។

សំឡាញ់របស់យើងម្នាក់ ថ្ងៃមួយគេជិនដោយតាំងមុខថា: គេនឹងត្រូវទៅនិយាយការនៅវេលាបច្ចុប្បន្ន ក្នុងការលៀងទទួលភ្ញៀវយ៉ាង

សំខាន់មួយកន្លែង ។ សំឡាញ់នោះនៅតែហាក់ដូចជាមួយនឹងយើង យើងឃើញគេរវល់រវៃតែចំពោះរឿងដែលខឹងទាំងនិយាយតែម្យ៉ាង គេភ្លេចទ្រង់ "សំឡេង" របស់គេទៅផង គេភ្លេចការពារខ្លួននឹងប្រុងប្រៀបគួរឿង "សំឡេង" ក្នុងគ្រាដំបូង ។ ថ្ងៃនោះយើងឮនឹងគេនិយាយអន់ជាទីបំផុត អន់ត្រឹមតែជាងដែលធ្លាប់និយាយមកពីកាលមុន ។

"ការប្រុងប្រៀបខ្លួនក្នុងវេលាដែលគេមិនទាន់មកដល់ ជាបទរៀនដ៏មិនស្លាប់របស់អ្នកគិតស្លូតទៅ!" ។

បទរៀននេះជាគំនិតប្រាជ្ញារបស់អ្នកប្រាជ្ញ "ភ្លេស៊ើរ" ការមេរក ប្រាប់វិធីសាងសំឡេងក្នុងខាងដើមខុកថា : "អ្នកត្រូវហាត់រាល់ថ្ងៃ ហាត់ទាំងការអានទាំងការនិយាយ ។

## ៥– ការហាត់អាន

ដើម្បីជួនឲ្យហាត់អានអក្សរជាមុន ។ អក្សរដែលល្អក្នុងការហាត់អាននោះ គឺសម្បុត្រដែលអ្នកផងគេសរសេរ (មិនមែនបោះពុម្ព) មកដល់យើង ។ ប៉ុន្តែត្រូវជ្រើសរើសយកតែសម្បុត្រ ដែលមានសេចក្ដីសារសព្វយ៉ាងពិស្ដារ ហើយឲ្យមានអក្សរល្អល្អនិងមានឃ្លាល្បះត្រឹមត្រូវផង ។ កាលបើបានសម្បុត្រដូចនេះហើយ គេឲ្យប្រតិបត្តិតាមវិធីដូចតទៅនេះ :

ក) ឱ្យរកទីកន្លែងណាមួយដែលស្ងាត់ គ្មានមនុស្សទៅធ្វើឱ្យរំខានបាន ហើយកុំឱ្យក្តៅស្អុះពេក កុំឱ្យមានពន្លឺខ្លាំងពេក កុំឱ្យងងឹតពេក រាំងកុំឱ្យពន្លឺព្រះអាទិត្យចាំងភ្នែក ។

ខ) ឱ្យឈរឬអង្គុយ (គេច្រើនប្រើឈរ) តាមសម្រួលដែលស្រួលបំផុត ដៃឆ្វេងកាន់សម្បុត្រ ដៃស្តាំចាប់ជ្រុងសម្បុត្រម្ខាង លើកឡើងឱ្យល្មមប្រមាណ កុំឱ្យជិតភ្នែកពេក-ឆ្ងាយពេក កុំសំឡឹងមើលឱ្យហួសកំឡាំងភ្នែក មើលតាមតែប្រក្រតីដែលយើងធ្លាប់មើល ។

គ) អានមួយៗ ឱ្យច្បាស់ៗ កុំឱ្យញាប់ពេក-រន្ថើលពេក កុំឱ្យតឹងសំឡេងពេក-ធូរពេក ឱ្យមានឃ្លាមានល្បះ និងត្រូវកំណត់សេចក្តីនៃវណ្ណយុត្តិដែលគួរបង្អង់គួរឈប់ ហើយត្រឡប់មើលសារជាថ្មីវិញ ឱ្យបានច្រើនៗដង ទាល់តែស្ទាត់ក្នុងវិធីអាន ឃើញថាត្រឹមត្រូវហាក់ដូចហើយ រកសម្បុត្រដទៃៗ មកមើលទៀត តាមវិធីដូចគ្នា ។

ឃ) អានយ៉ាងញាប់រួសរាន់ តែឱ្យច្បាស់ៗ និងត្រូវប្រើឃ្លា-ល្បះដូចមុន ។

ង) អានយ៉ាងញាប់រួសរាន់បំផុត ដូចជាលោកសូត្រមេសូត្រ ដែលចាំស្ទាត់ហើយ ដោយមិនឈប់ឃ្លា-ល្បះ តែឱ្យច្បាស់ៗ កុំឱ្យព្រលាំៗ ។

ក) កាលបើស្ទាត់ជំនាញហើយ ត្រូវរកសម្បុត្រដែលមានអក្សរមិនស្រួលច្បាស់លាស់មកអាន តាមលំដាប់ត្រង់គ, ប្រព្រឹត្តិយ, ទីផង, ផ្គុបដល់ស្ទាត់ ហើយរកសម្បុត្រដែលមានអក្សរយ៉ាងពិបាក មកហាត់អានតាមវិធីដូចគ្នា ទាល់តែឃើញថាស្ទាត់ជំនាញក្នុងការអានប្រាកដមែនទាំងក្នុងក៏ដែរ ទោះបីអក្សរវៀចយ៉ាងណា ឬសម្បុត្រមានសេចក្ដីមិនសូវល្អមានឃ្លាល្បះមិនត្រឹមត្រូវដូចម្ដេច ក៏អាចកាត់ទម្រាយយល់សេចក្ដីបានច្បាស់លាស់ទៅបាន ដោយឥតមានកំហុសច្រឡំឬស្ទើរស្ទាក់ ទាំងពុំបាច់សំឡឹងមើលអក្សរប៉ុន្មាន តាមពេលខ្លះក្រឡេកមើលឬងើបមុខមើលទៅទិដ្ឋខាងក៏បាន នៅតែអានមិនទាក់មិនគាំងហើយសង្ក្រោះក្បាយផង ទុកជាមិនបានមើលទុកជាមុនក៏ដោយ ។

តាមវិធីដែលពោលមកនេះ បើលោក-អ្នកហាត់អានតាមជម្រិតបញ្ចប់បានហើយ រមែងបានទទួលផលច្រើនប្រការគឺ: មានសំឡេងក្បោះក្បាយច្បាស់លាស់គួរឲ្យជាទីស្ដាប់ ទោះបីញាប់ឬរន្ថើលក៏ដោយមានក្នុងក្រ-ប្រាតិរឹងប៉ឹង - អង់អាចក្នុងវិប្រជុំ សំឡេងមានទម្ងន់គួរឲ្យជឿស្ដាប់ធ្វើឲ្យអ្នកស្ដាប់ៗ ងាយយល់ចូលចិត្តបានឆាប់ ទីផងអាចយល់សេចក្ដីនៃពាក្យពេចន៍គ្រប់យ៉ាងដោយខ្លួនឯងបានជាដើម ហើយជាវិធីទំនុកបម្រុង

ភ្នែក ដែលជាកាយគុណសំខាន់បំផុតមួយ ឲ្យមានសេរីភាពទាក់ទាញត្រៀង ដៃជើងប្រសើរផង ៗ បន្ទាប់អំពីនេះទៅ ត្រូវចូលកាន់ចង "ហាត់និយាយ" តទៅទៀត ៗ

## ៦– ការហាត់និយាយ

ដើម្បីបង្ហាត់ឲ្យហាត់និយាយម្នាក់ឯងជាមុន ៗ ត្រូវរកទីកន្លែងដែលមានខ្យល់អាកាសល្អបរិសុទ្ធ ដូចយ៉ាងទីវាល សួនច្បារ ទីដងមាត់ទន្លេជាដើម (នៅប្រទេសក្រិក គេច្រើនទៅហាត់នៅមាត់សមុទ្រឬកោះណាមួយដែលមានខ្យល់អាកាសល្អ) ៗ ហាមមិនឲ្យហាត់ក្នុងពេលដែលមានសូរ្យរស្មីក្តៅខ្លាំង ឲ្យហាត់តែពេលព្រឹក ល្ងាច និងយប់ និងហាមមិនឲ្យហាត់ក្នុងវេលាដែលទើបបរិភោគអាហាររួច ត្រូវបង្អង់ឲ្យអាហាររលួយសិន (នេះហាមចំពោះតែគ្រាដែលហាត់ដំបូង ដល់ស្ទាត់ទៅត្រូវហាត់ទាំងពេលក្តៅទាំងពេលទើបបរិភោគហើយក្តី) ៗ ត្រូវហាត់ទាំងឈរ ទាំងអង្គុយ តែត្រូវរៀលតាមសម្រួលដែលស្រួលជាងបំផុត; ក្នុងការហាត់និយាយឈរ ត្រូវហាត់ទាំងឈរទុចដៃ ទាំងសម្រេចដៃ ទាំងធ្លាដៃ, ក្នុងការហាត់អង្គុយនិយាយ ត្រូវហាត់ទាំងអង្គុយបត់ជើង ទាំងលុតជង្គង់ ទាំងអង្គុយកៅអី តែទាំងដំហារទាំងបង្គុយ ត្រូវទប់ដងខ្លួនឲ្យនឹង កុំឲ្យយោលឬងឹកងោកដូចគ្នា ៗ ក្នុងការហាត់និយាយនេះ ក៏មានដំណើរទំនងដូចការហាត់អានដែរ គឺគេឲ្យធ្វើដូច្នេះ: (មានត)

# តម្រូវតាមសេចក្តីត្រូវការរបស់ធម្មជាតិ

ហ៊ុននិពន្ធមន្ត្រី ញ៉ុក-ថែម ប្រែ-រៀបរៀង

(តមក)

មិនចូលចិត្តលេងកីឡាហាត់ប្រាណ ច្រើនតែចូលចិត្តស៊ីផឹកៗ ដូច្នេះ ជាគ្រឿងដាស់កាមារម្មណ៍ឲ្យចំរើនឡើងទាំងអស់ ។

ឯអ្នកដែលមានកំឡាំងចិត្តរឹងប៉ឹង និងកំឡាំងកាយក៏ខ្លាំងត្រឡប់ជាមានចិត្តគិតនឹក ក្នុងកាមារម្មណ៍តិចជាង ។

ឃ - **អំពីព្យាធិក្នុងរាងកាយ** — រោគចំពូកខ្លះ នាំឲ្យកើតកាមារម្មណ៍ខ្លាំងក្លាឡើង តែរោគខ្លះធ្វើឲ្យទន់ខ្សោយទៅវិញ ។ អ្នកដែលកើតរោគរបេងរ៉ាំរ៉ៃ ច្រើនមានដម្រេកក្នុងកាមរាគ ។ រោគប្រមេះដែលមិនទាន់សាហាវខ្លាំងក៏អាចធ្វើឲ្យមានដម្រេកខ្លាំងដែរ ប៉ុន្តែរោគចំពូកណា ដែលធ្វើឲ្យអន្តរាយដល់សួតឬអណ្ឌៈ នោះនាំបន្ថយដម្រេកក្នុងកាមរាគៈ ឬអស់ដម្រេកទៅបាន អ្នកដែលបានសេពសន្ថវកិច្ចច្រើនហួសប្រមាណ ក៏ជាហេតុនាំឲ្យថយខ្សោយកាមរាគៈទៅបានដែរ ។

ង - **វត្ថុផ្សេងៗ ដែលនៅជុំវិញ** — អស់នេះហើយជាគ្រឿងជ្រោមជ្រែងបន្ថែម ឬបន្ថយកាមរាគបានដែរ ។ គ្រឿងជួយចិត្តគំនិតឲ្យមានដម្រេកស្រើបស្រាលក្នុងកាមារម្មណ៍ ដូចជាតន្ត្រីក្តី ល្ខោនក្តី

របាំក្តី មហោស្រពដែលនាំឲ្យស្រើបកាមារម្មណ៍ដទៃទៀតក្តី សៀវភៅតម្រាទិយាយពីកាមារម្មណ៍ក្តី រូបគំនូរ រូបថតដែលនាំសើបក្តី ។ល។ អស់នេះសុទ្ធតែជាគ្រឿងនាំឲ្យបំរើនកាមារម្មណ៍ទាំងអស់ ។

## អារម្មណ៍ដែលនាំឲ្យរីករាយចិត្ត

រាងកាយរបស់យើងប្រកបដោយជីវិត តែងការប្រែកទីងយ៉ាតក្តាក់ទំពារ តាមធម្មតារបស់ដែលមានជីវិត តែងមានអាការទៀយហត់ ស្រេកឃ្លាន ក្រៅពីការសម្រាក តាមធម្មតានៅមានអាហារសម្រាប់បំរុងកងកាយ ឲ្យស្រស់បស់មានកំលាំងធ្វើការតទៅទៀត ។ ឯចិត្តជាគ្រឿងរះដ៏សំខាន់របស់មនុស្សបុគ្គលដូចជាងកាយដែរ ហើយអាហារដ៏សំខាន់របស់ចិត្តគឺអារម្មណ៍ ដែលនាំចិត្តឲ្យសប្បាយរីករាយហ៊ឹងឯង ។ ឯគ្រឿងដែលនាំឲ្យកើតសេចក្តីរីករាយដល់ចិត្តគំនិត ប្រសិនបើញែកចេញជាប្រភេទ ៗ ដូចនេះ

១ - តន្ត្រីគ្រប់ប្រភេទ

២ - មហោស្រពផ្សេងៗ

៣ - ការប្រឡងកីឡាលេងកន្ទុង ផ្ទាល់ខ្លួនឯង

៤ - សៀវភៅប្រលោមលោកនិងគំនូរផ្សេងៗ

៥ - ការនិយាយប្រាប់និងលេងសើច ជាមួយនឹងមិត្តភក្តិគ្រួសារ នឹងការសមាគម ។

៦ - បកិណ្ណកៈការងារ

៧ - ការដើរលេងកំសាន្តចិត្ត

៨ - កាមារម្មណ៍

គឺឡាគ្រប់ប្រភេទ បើយើងប្រព្រឹត្តតែល្មមប្រមាណតាមសមគួរ ទីនេះសេចក្ដីត្រេកអររបស់កាយ រមែងជាគុណទាំងអស់ឥតទោសបន្តិចឡើយ ។ ឯរបស់ដែលនាំឲ្យចិត្តរីករាយផ្សេងៗទៀត ដូចជាមហោស្រព កាមារម្មណ៍ជាដើម គាប់ភេទទាំងទោស ទាំងគុណ ។

## អំពីការងារដែលធ្វើដោយកំឡាំងកាយ

មនុស្សយើងកើតមក ទុកជាមានទ្រព្យធនធានមិនចាំបាច់ឲ្យយើងធ្វើការក៏មាន ប៉ុន្តែធម្មជាតិរបស់កាយយើង បង្គាប់ឲ្យត្រូវតែធ្វើការ ធម្មជាតិមិនបានសាងយើងមក ឲ្យនៅនឹងថ្កល់ដូចដើមឈើ គឺត្រូវការឲ្យធ្វើការកម្រើកទៅមកជានិច្ចឲ្យសមនឹងភាវៈជារបស់មានជីវិត ប្រភេទដែលឃ្លាតចាកទីឋាន មានដៃសម្រាប់ធ្វើការ មានជើងសម្រាប់ដើរ ។ ប្រសិនបើយើងមិនប្រើអវយវៈទាំងនេះ ឲ្យប្រព្រឹត្តទៅតាមបំណងធម្មជាតិទេ / មុខជាធម្មជាតិធ្វើទោសយើង គឺឲ្យទៅជាអ្នកមានរោគកាយ ទ្រុឌទ្រោមទៅភ្លាម ទាំងមានកាយរូបមិនមាំ ។ សូមឲ្យសង្កេតមើលចុះ បុគ្គលណាធ្វើការងារដោយកំឡាំងកាយ បុគ្គលនោះរមែងមានរាងកាយមាំចំណាប់ ទាំងសុខភាពល្អផង តែបុគ្គលដែលខ្ជិលច្រអូស ឬ អ្នកធ្វើ

ការច្បិចច្បើម ការធ្វើមិនធ្វើ ការស្រោលក៏មិនព្រមធ្វើ ពលកាយបុគ្គល បំពួកនេះ ច្រើនទន់ខ្សោយមិនមានកំឡាំងខ្លាំងពូកែទេ ទុកជាមាន សាច់ដាត់មាំពលកាយធំហើងណាក៏ដោយ ក៏ច្រើនតែជាមនុស្សខ្សោយ មានកំឡាំងតិច អាយុខ្លី ។ តាមធម្មតា ការណាដែលត្រូវប្រើកំឡាំង កាយ ឬនាំឲ្យចេញកំឡាំងកាយ ការនេះសុទ្ធតែជាការមានគុណ ប្រយោជន៍ដល់ពលកាយទាំងអស់ ដូចជាការធ្វើចម្ការ, ធ្វើសួន, ធ្វើស្រែ, ធ្វើម៉ៅព្រៃ, ធ្វើការជីកលោហធាតុ និងប្រើកំឡាំងកាយលើសែងផ្សេងៗ ការងារនៅខាងផ្ទះ ។ល។ ពួកកម្មករនិងកសិករ ច្រើនតែមានពល កាយមាំបំណាច់ ហើយបានកំឡាំងកាយច្រើន ដោយហេតុការងារពុំចប់មិន ឈប់ ជាប់ខាងការប្រើកម្លាំងកាយជានិច្ច ។ ការងារប្រភេទអស់នេះ ជាថ្នាំចំរើនអាយុយ៉ាងវិសេសរបស់ពលកាយ ជាការកសាងកម្លាំងនៃ បុគ្គលផងចិត្តផង ។

ពិតមែនតែពលកាយ ដែលត្រូវធ្វើការដោយកម្លាំងកាយ ប៉ុន្តែ យើងក៏មិនត្រូវធ្វើការគ្រប់ចំពូក ដោយកំឡាំងកាយតែម្យ៉ាងទេ យើង ត្រូវរើសជ្រើសតាមផ្លូវកណ្តាល គឺប្រើកំឡាំងកាយធ្វើការច្រើនហួសពេក ក៏ពុំបាន តិចហួសពេកក៏ពុំបាន ។ យើងមិនត្រូវធ្វើបំបាក់កំឡាំង របស់យើងទេ គឺយើងត្រូវធ្វើដោយមានរយៈឈប់សម្រាកតាមសមគួរ

និងកំឡាំងរបស់យើង ។ ប្រសិនបើធ្វើការតាមប្រមាណនៃកំឡាំងរបស់យើងហើយ មុខជាមានតែគុណឥតទោសភ័យអ្វីឡើយ ។

## អំពីការឈប់សម្រាក

តាមធម្មតា កាលបើយើងបរិភោគហើយ តែងបន្ទាបពេញយ៉ាងណា រាងកាយយើង កាលបើធ្វើការតម្រែតទាល់តែនឿយហត់ហើយ គេក៏តែឈប់សម្រាកដូច្នោះដែរ បើមិនធ្វើដូច្នេះទេ រាងកាយក៏ទ្រុឌទ្រោមទៅជាចាប់ ការឈប់ដេកសម្រាកជាកិច្ចមួយ ដែលនាំឲ្យអវយវៈគ្រប់ចំណែករបស់រាងកាយនៅស្ងប់ស្ងៀម និងបើកឱកាសឲ្យរាងកាយធ្វើការជួសជុលកន្លែងដែលសឹករេចរឹលទៅ ឲ្យបរិបូណ៌ដូចដើមឡើងវិញ ។ ផលនៃការដេកសម្រាកកាយនេះ កាលភ្ញាក់ឡើង រមែងមានកំឡាំងថ្មីមាំផាត់ទៀតហាក់ ប្រមាណជម្ងឺឈឺចាប់បន្តិចបន្តួច ដូចរលមុខឈឺក្បាលជាដើម ក្រោយដែលបានដេកលក់ស៊ប់ស្កប់ជាវេលាយូរល្មមសមគួរហើយ រមែងមានអារម្មណ៍ស្រស់បស់ឡើងច្រើន ។ ការដេកលក់ស៊ប់ស្កប់ជាការខានពុំបាន ប្រហែលនឹងអាហារដែរ បើមិនមានការដេកសម្រាកហើយ រាងកាយរបស់យើងមុខជាមិនមានឱកាសជួសជុលអវយវៈដែលសឹករេចទៅឡើយ ។

តាមធម្មតា មនុស្សយើងមិនគួរធ្វើការឲ្យលើសពី ៧ ឬ ៨ ម៉ោងក្នុង ១ ថ្ងៃទេ ៦ ៧ ឬ ៨ ម៉ោងទៀតជាពេលសម្រាក ពេលទំនេរ

ខាង ទឹងការស្រែករធអារម្មណ៍ជាទំនោរកាយដល់ចិត្ត ៦ ៧ ឬ ៨ ម៉ោង ទៀតជាពេលដេក ។ ការដេកថ្ងៃមិនមែនជាការសំខាន់ទេ គួរតែប្រើ ពេលដេកតែក្នុងវេលាយប់ប៉ុណ្ណោះ ហើយគួរចាប់ដេកតាំងពីម៉ោង ២១ ទៅ ដល់ ម៉ោង ៦ ក្ដីសីមព្រោក ត្រឹមប៉ុណ្ណោះប្រសើរណាស់,មួយ វិញទៀត គួរហាត់ជាអ្នកដេកស៊ាយ គឺដេកឲ្យលក់បានមិនបាច់ ក្រឡុកក្រឡាប់នៅកន្លែងណា ទុកជាទីដេកនោះផ្លាស់ទីងដីវង ឬដេកលើដំ-ណេកដ៏ទន់ក្ដី ក៏អាចដេកឲ្យលក់ទៅបានដូចគ្នាទាំងអស់ ។ ការហាត់ ដេកទម្លាប់ខ្លួនទំនងនេះ រមែងមានផលល្អតែម្យ៉ាង ដល់គ្រាក្រលំបាក គោក្រយ៉ាក រាងកាយរបស់យើង ក៏មិនទ្រុឌទ្រោមដោយហេតុដេកក មិនលក់នោះឡើយ ៕

## អំពីការប្រើខួរក្បាល

ការប្រើខួរក្បាលនេះ សំដៅដល់ការប្រើខួរក្បាលឲ្យបេះតិចឲ្យ ដេះដាំ ។ វិធីប្រើខួរក្បាលក្នុងលោកសព្វថ្ងៃនេះ កំពុងចំរើនណាស់ ដែរ មិនចាញ់ការពួកធ្វើការ ដោយកំឡាំងកាយទេ ប៉ុន្តែការធ្វើការ ដោយខួរក្បាល ជាការដែលកាន់តែមិនសូវត្រូវការទេ ដោយ ហេតុការងារប្រភេទនេះ នាំឲ្យទ្រុឌទ្រោមដល់សរីរៈ ដែលត្រូវ ប្រើត្រាំត្រែង ឯអ្នកដែលធ្វើការដោយកំលាំងកាយ ទុកជាធ្វើ ត្រាំត្រែងមិនគិតម៉ោងពេលក៏ដោយ អ្នកធ្វើការទំនងនេះក៏ឡើងតែមាន.

កំឡាំងកាយកំលាំងចិត្តអាយុយើងដែរ  តែអ្នកដែលធ្វើការនឹងខួរក្បាល យ៉ាងម៉ឺងម៉ាត់ ហើយជួនហួសកំណត់ពេលនាំឲ្យកើតទោសដល់កងកាយ និងចិត្តគំនិតជាអនេកប្រការ  គឺច្រើនតែមានរោគងាយស្មារតីស្ពុង សាប់ស្ពាំងកើតរោគខាងសរសៃប្រសាទ  ហើយមានអាយុមិនយឺន ៗ អ្នកដែលខូចខួរក្បាលឬឆ្កួតលីលា  ដែលជាផលកើតមកអំពីការប្រើខួរក្បាលហួសកំណត់  ទម្រាំនឹងគ្រូពេទ្យថែរក្សាឲ្យសះជាផង  ហើយស្រឡះណាស់ ៗ នៅប្រទេសដែលមានសេចក្តីចំរើនច្រើន ដូចសហរដ្ឋអាមេរិក មានមនុស្សធ្វើការដោយខួរក្បាលកាន់តែច្រើនឡើងៗ  ហើយអ្នកដែលកើតរោគខួរក្បាលពិការ  ក៏កាន់តែមានចំនួនច្រើនឡើងៗ ដែរ ។

ទុកជាយ៉ាងណាក៏ដោយ លោកធាតុរបស់ថ្ងៃនេះមិនមែនជាលោកធាតុកាលបុរាណ ១០០៦ ឆ្នាំមកហើយនោះទេ  គឺជាលោកដ៏ដេរដាសទៅដោយការនេទ្ធះអន្ទង ពាសពេញទៅដោយការប្រណាំងប្រជែង ស្វែងរកសំណាងនឹងទ្រព្យសម្បត្តិស្ទើរតែទាំងអស់  ចុះក្នុងជាគ្រឿងនាំផ្លូវទៅកាន់បំណងដូចនេះបានសម្រេច ?  មិនមានអ្វីវិសេសជាងការប្រើខួរក្បាលឡើយ  ហេតុនេះហើយបានជាមនុស្សសព្វថ្ងៃនេះ  ចាំមែនតែប្រឹងគ្រប់ៗបរមាណូនៃកងកាយ  គឺគោលចង់ប្រើអវយវៈគ្រប់ៗចំណែកនៃកងកាយ ដើម្បីឲ្យបានសម្រេចផលប្រយោជន៍ដូចពោលមកហើយ  នេះហើយជាបាបគ្រោះរបស់យើងដែលកើតមកក្នុងលោកដែលមានសភាពដូច្នេះ ៗ

(មានត)

# យុគសុន្ទរមេធី ញង់-សឿង ប្រែ

## លោក ហង់-គីមសេង ពិនិត្យ

(តមក)

---

អ្នកដែលត្រូវការចង់មើលគេចងព្យួរកអគ្គមហាសេនា សម្លាប់ចោលព្រមទាំងផៅសន្តាន ៤០ នាក់ ចូរនាំគ្នាទៅឯកន្លែងកាន់ទុក្ខព្រះរាជកំណត់ពេលឥឡូវនេះ » ។

លុះគេរៀបចំជីកដាំសសររួចស្រេចហើយ ទើបទៅក្រុមម្នាក់ផាបាន-ហ្វាន់សាលា ក្រឹត្តទីនពួកព្រះរាជការផ្ញាផាប្រើឲនាក់ នាំអគ្គមហាសេនាបួបអន្ទើដោយញាតិផៅសន្តានទាំង ៤០ នាក់ មកឲ្យអង្គុយតំរៀបគ្នាក្បែរសសរនោះហើយគេយកខ្សែមកចងកគ្រប់ ១ គ្នា ដើម្បីទីងផាក់ខ្សែរឹតទាញយកជីព្រះខ្សែទៅលើ ។ ពួកបណ្តាកស្ត្រីដែលឈរមើលមរណៈដោយនោះ មិនអាចឈរមើលដោយព្រះសេចក្តីតក់យទេ គឺស្ទុះឈរមើលទាំងមានសេចក្តីខ្លាចព្រៃយ ស្រែកស្រដៀកហើយសម្រក់ទឹកភ្នែកគ្រប់ ១ គ្នា ព្រោះអគ្គមហាសេនាទីមួយវង្សត្រកូលរបស់លោកធ្លាប់មានសេចក្តីសុចរិតស្លូតត្រង់ ចិត្តទូលំទូលាយ គិតផលប្រយោជន៍ដល់សាធារណជនដែលសេមុខ ហើយផាំងស្រែទ្បាញ់ពេញចិត្តនៃបណ្តាកស្ត្រីទាំងអស់ ទាំងកុងក្រុងទីទ័រម្មខេត្តក្រៅផ្សេងៗ ក្នុងព្រះនគរទាំងមូល ។

បើទុកជាដូច្នោះ ក៏ឥតមានអ្នកណាមួយហ៊ានដៃឥតកំណរពារ ឧទ្ទិនរំដៀបទើនតាញ្ញហើនផាប់ខាតរបស់ព្រះកញ្ញាអគ្គនេះបានឡើយ ។ គង់តែពេលដែលគេកំពុងរៀបចំក្មេងយាតនកម្មផ្តាច់ជីវិតនៃពួកជនសុចរិតទាំង , អម្បាលនោះ ស្រាប់តែឃើញបុរសម្នាក់មានរូបរាងស្រស់បស់ ស្លៀកពាក់ខោអាវយ៉ាងស្អាតបាត ដើរច្រៀតច្រែកពួកពលកណ្តាលចំណោមប្រជុំជននោះ ចូលមកក្រាបសំពះឧត្តមមហាសេនា ចាប់ដៃលោកធ្វើបាបហើយ ទើបទាស់ថាថា "ឱព្រះតេជព្រះគុណឧត្តមមហាសេនា ដែលជាអធិបតីនៃបណ្តាជនខាងសាសនាមហាយាត ដែលស្រោចស្រង់អ្នកកំសត់ទុគ៌ត ! លោកមិនមែនជាអ្នកមានទោសទេ ឧក្រិដ្ឋដែលត្រូវឲ្យគេចាប់យកមកសម្លាប់កន្លែងនេះទេ, សូមលោកមេត្តាលែងខ្លួនទៅចុះ ទុកឲ្យខ្ញុំបាទទទួលទោសឧក្រិដ្ឋនេះវិញ ព្រោះខ្ញុំបាទនេះឯងហើយដែលជាអ្នកសម្លាប់ស្ត្រីនេះយកទៅបោះចោលក្នុងទន្លេទ្រើ" ។

ទោះបីពាក្យសូមទទួលទោសនោះ មានទំនងគួរឲ្យឧត្តមមហាសេនាមានសេចក្តីត្រេកអរជាទីបំផុត ព្រោះលោកមុខជាបានរួចខ្លួនហើយ ក៏ប៉ុន្តែលោកមានសេចក្តីករុណាអាសូរពេកក្រៃ ដល់បុរសដែលមកខ្លួនមកទទួលទោសដោយឥតតក់ស្លុតខ្លួនបន្តិចសោះ ។ ក្នុងគ្រាដែលលោកឧត្តមមហាសេនា កំពុងតែសួរ ឆ្លើយ សាសន៍ជាមួយនឹងបុរសនោះ ស្រាប់តែលេចការាស់ម្នាក់មកដល់ទៀត ដើរប្រជ្រៀតញែកគេ

ឯងចូលមកក្រាបគល់អគ្គមហាសេនា ហើយទើបពោលថា៖ "ព្រះតេជ-ព្រះគុណ! សូមទាន់កុំជឿពាក្យរបស់បុរសនេះឲ្យសោះ ខ្លួនខ្ញុំបាទឯណោះទេ ជាអ្នកសម្លាប់ស្រីដែលគេបានឃើញក្នុងហិបនោះ ឥតមានអ្នកណាដទៃក្រៅអំពីរូបខ្ញុំបាទឡើយ, ខ្ញុំបាទសូមទទួលទោសនោះដោយខ្លួនឯង ហើយរឿងនេះខ្ញុំបាទហ៊ានស្បថតាំងសច្ចាយកព្រះជាប្រធាន, សូមលោកកុំផ្តន្ទាដល់មនុស្សដែលគ្មានទោសដូច្នេះ" ។ បុរសឆ្លើយតវ៉ាឡើងក្នុងចំពោះមុខលោកអគ្គមហាសេនាថា "ព្រះតេជព្រះគុណ! ខ្ញុំបាទសូមជំរាបដោយពិតប្រាកដ គឺខ្លួនខ្ញុំបាទហ្នឹងឯងហើយដែលបានធ្វើឃាតកម្មនោះ ឥតមានអ្នកណាក្រៅពីអំពីរូបខ្ញុំបាទទេ" ។ តាចាស់ឆ្លើយតាក់ឡើងទៀតថា "កូនប្រុសឪពុក! ខ្លួនអ្នកនៅក្មេងនៅឡើយ អ្នកកុំចង់មកផ្តូរជីវិតឲ្យស្លាប់ឥតសារផលតាមុនចាស់ដូច្នេះ ត្រូវតែអ្នករស់នៅដើម្បីរកស៊ីឲ្យមានបុត្រតាមព្រេងសំណាងរបស់ខ្លួនទៅចុះ, ចំណែកខ្លួនខ្ញុំនេះបានកើតមកយូរយារណាស់ហើយ ចាស់ទាំងខ្លួនស្កូវទាំងសក់, ទាំងកិច្ចការសុខទុក្ខក្តៅត្រជាក់រាក់ជ្រៅអាក្រក់ល្អយ៉ាងណា, ក៏ខ្ញុំបានស្គាល់សព្វគ្រប់ទាំងអស់ ពេលនេះក៏ល្មមស្លាប់ដែរហើយ ត្រូវតែអ្នកឯងបណ្តោយទុកឲ្យខ្ញុំបូជាជីវិតជំនួសវិញ អ្នកកុំដែដកហ៊ាប់ជាអ្វីទៀត" ។ រួចហើយតាចាស់ក៏ងាកទៅនិយាយនឹងអគ្គមហាសេនាថា "ព្រះតេជព្រះ-

គុណ! ខ្ញុំបាទសូមជំពាបបន្ថែមមួយទៀតថា គឺពិតប្រាកដជារូបខ្ញុំបាទនេះឯងហើយដែលជាអ្នកពិឃាតស្រីនោះ, សូមលោកសម្លាប់ខ្ញុំឥឡូវនេះចុះ កុំសង្ស័យ" ។

ពាក្យដែលតក់ចុះឡើង រវាងតាចាស់នឹងបុរសនោះ នាំឲ្យអគ្គមហា-សេនាងងឹងងងល់គំនិត មិនដឹងជាគិតទៅផ្លូវណា ទើបសុំអនុញ្ញាតច្បាប់អំពីចៅក្រមនិងព្រះរាជអាជ្ញាដែលជាអ្នកត្រូវត្រាការនោះ ហើយក៏នាំបុរសទាំងពីរនាក់ចូលទៅក្រាបទូលព្រះបាទកាលិង្គ ។ កាលនាំចូលទៅដល់ហើយ អគ្គមហាសេនាលុតជង្គង់ក្រាបថ្វាយបង្គំប្រាំពីរដង រួចក្រាបបង្គំទូលថាផ្ទូះផ្ទះ "បពិត្រព្រះករុណាថ្លៃវិសេស! តាចាស់នឹងបុរសនេះឆ្លើយទទួលទោសខ្លួនឯងចំពោះរូបម្នាក់ ៗ ថា បានសម្លាប់ស្រីនោះ, ឥឡូវនេះទូលបង្គំសូមនាំយកមកក្រាបទូលព្រះករុណា ដើម្បីឲ្យទ្រង់បានជ្រាបតាមដំណើរ" ។ គ្រានោះ កាលិង្គទ្រង់ត្រាស់សួរគ្នាថា "បណ្ដាអ្នកទាំងពីរនេះ តើអ្នកណាដែលបានសម្លាប់ស្រីនោះ ហើយយកទៅបោះចោលក្នុងទន្លេទីត្រាំ" ។ បុរសក្រាបទូលមុនគេថា គឺខ្លួនឯងពិតប្រាកដ, ប៉ុន្តែតាចាស់ឆ្លើយទទឹងទាស់មកវិញថា ខ្លួនគាត់ឯណោះទេដែលបានសម្លាប់ស្រីនោះ ។ កាលិង្គមានបន្ទូលចំពោះអគ្គមហាសេនាថា "បើដូច្នោះបួរអ្នកឯងនាំយកក៏ទៅសម្លាប់ទាំងពីរនាក់ទៅ" ។ អគ្គមហាសេនាក៏ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស! បើអ្នកដែលត្រូវមាន

ទោសទណ្ឌនោះមានតែម្នាក់ទេ   នឹងសម្លាប់ម្នាក់ទៀតដូចម្ដេចកើត ព្រោះរឿងនេះ   នៅទាក់ទាមមិនទាន់ដាច់ស្រេចទៅខាងណានៅឡើយ, កាលបើយកទៅសម្លាប់តាំងពីទៀតយ៉ាងនេះ ឈ្មោះថាអយុត្តិធម៌ពេញទី" ។

កាលអគ្គមហាសេនានិយាយពាក្យនេះរួចហើយ  បុរសនោះឆ្លើយឡើងទៀតថា "សូមទ្រង់ព្រះមេត្តាប្រោស! រឿងនេះទូលបង្គំហ៊ានស្បថប្រណិធានយកព្រះមកជាទីតាំងថា  ពិតជារូបទូលបង្គំនេះប្រាកដមែន ដែលបានសម្លាប់ស្រីនេះកាត់ជាកំណាត់ៗ  ដាក់ក្នុងហឹបហើយយកទៅបោះចោលក្នុងទន្លេទីគ្រ៍,  គិតតាំងពីថ្ងៃសម្លាប់នោះមកទល់នឹងថ្ងៃនេះបាន ៤ ថ្ងៃហើយ ។ ទូលបង្គំមិនបង់ឲ្យជាប់ពាក់ទងដល់អ្នកដទៃទៀតទេ  ក្នុងថ្ងៃដែលត្រូវកាត់ទោស,  ទូលបង្គំសូមទទួលទោសទណ្ឌនោះដោយខ្លួនឯង   ព្រោះខ្ញុំបានប្រព្រឹត្តបទកំហុសដូច្នោះមែន" ។ ព្រះបាទកាលិហ្វ   ទ្រង់មានសេចក្ដីស្ងើចស្ងាល់ណាស់នឹងសំដីនោះ ហើយទ្រង់ជឿជាក់ប្រាកដថា  គឺបុរសនោះឯងហើយដែលជាអ្នកសម្លាប់ ព្រោះគាត់ឆាស់ផ្ទាត់មាត់ពបឹងលែងហ៊ានឆ្លើយតតទៅទៀត   ទើបទ្រង់ងាកបែរទៅត្រាស់សួរបុរសនោះថា "នែប្រស្ន, ដោយមានហេតុផលដូចម្ដេចបានជាអ្នកឯងហ៊ានប្រព្រឹត្តកំហុសយ៉ាងធ្ងន់ ដែលគេគួរស្អប់ខ្ពើមយ៉ាងនេះ? ហើយដោយយល់ឃើញយ៉ាងណា  ក៏បានជាស៊ូប្រថុយជួល

ខ្លួនមកឲ្យគេសម្លាប់ឯងវិញ ហើយនេះ ។ បុរសក្រាបទូលថា "បពិត្រព្រះសម្មតិទេព រឿងដំណឹងហួសទៅហើយ របស់ស្ត្រីនោះនឹងទូលបង្គំនេះ ប្រសិនបើគេគប់សរសេរជារឿងទុកក្នុងក្បួនខ្នាតនោះ នឹងបានទៅជារឿងមួយដ៏មានប្រយោជន៍ហើយសំខាន់ដល់មនុស្សទាំងពួង" ។ ចាល់ហ៊ូក៏មានបន្ទូលថា "អើបើដូច្នោះ បូរឯងនិយាយចុះ យើងបើកឱកាសឲ្យ" ។ បុរសបានទទួលតាមព្រះរាជឱង្ការហើយ ក៏ចាប់ផ្ដើមនិយាយរឿងការរបស់ខ្លួនដូចមានសេចក្ដីតទៅខាងក្រោយនេះ៖

## រឿងស្រីដែលគេសម្លាប់នឹងបុរសជាស្វាមីរបស់នាង

បពិត្រព្រះអង្គជានាយកនៃបរិស័ទ! ព្រះករុណាថ្លៃវិសេសគង់នឹងបានជ្រាបថា ស្រីដែលទទួលមរណកាលនោះ ជាភរិយារបស់ទូលបង្គំហើយត្រូវជាកូនស្រីនៃតាព្រឹទ្ធាចារ្យនេះឯង ។ ឯតានេះសោតត្រូវជាមារបស់ទូលបង្គំខាងឪពុក គិតទៅនាងជាភរិយានោះជាប់ជាសាច់ញាតិជិតណាស់ គឺត្រូវជាបងប្អូនជីដូនមួយបង្កើត ។ តសំណោកបាសចុំបានរៀបចំផ្សំផ្គុំឲ្យជាភរិយាស្វាមី តាំងពីនាងនេះទើបនឹងបានអាយុ ១២ ឆ្នាំម្ល៉េះ ហើយបើកចាប់ផ្ដើមតាំងអំពីកាលដែលរៀបចំអាពាហ៍ពិពាហ៍ហើយរហូតមកដល់ឥឡូវនេះ បានចំនួន ១១ ឆ្នាំហើយ ។ ទូលបង្គំមានកូនប្រុស ៣ នាក់សព្វថ្ងៃនេះនៅរស់នៅឡើយ, ភរិយាទូលបង្គំនោះ មានកិរិយាមារយាទស្លូតបូតសុភាពរាបសារម្យទំល្អណាស់

ហើយតាំងពីកប់ប្រុសចាប់ដៃគ្នាមក ។ នាងតែងទទួលស្គាល់បង្គាប់ទូលបង្គំតាមច្បាប់ទម្លាប់ មិនដែលធ្វើឲ្យទូលបង្គំទុស្សានដល់ម្ដងទេ ។ ចំណែកខាងទូលបង្គំវិញ ក៏ស្រឡាញ់នាងទុកដូចជាថ្លើមប្រមាត់ហើយ តែងបំពេញអាស្រ័យនាងទាំងអស់ មិនដែលទទឹងទាស់ធ្វើឲ្យនាងអាក់អន់ចិត្តឡើយ ។

ប្រហែលជាពីរខែកន្លងមកហើយ នាងចាប់មានជម្ងឺ ។ ទូលបង្គំមានសេចក្ដីភិតភ័យខ្លាំង ហើយខំស្វះស្វែករកថ្នាំសង្កូវផ្សេងៗ មកព្យាបាលយ៉ាងម៉ឺងម៉ាត់តគ្មានខាតទ្រព្យសម្បត្តិសោះ ព្រោះចង់ឲ្យនាងបានជាឆាប់ ៗ លុះខំប្រឹងព្យាបាលចំនួនមួយខែទើបនាងបានគ្រាន់បើ ល្មមដើរទ្រេត ៗ បាន ហើយនាងចង់ចេញដើរទៅងូតទឹក ។ មុននឹងក្រោកចេញដើរពីផ្ទះទៅងូតទឹកនោះ នាងនិយាយនឹងទូលបង្គំថា "អ្នកបង ខ្ញុំឆាប់ឆ្ងាត់ហើយចេះតែនឹកចង់ទទួលទានផ្លែទន្លាប់ ប្រសិនបើបងរកបានមែន សមបើខ្ញុំនឹងសប្បាយចិត្តណាស់ហោង; ខ្ញុំនឹកចង់ទទួលទានផ្លែទន្លាប់នេះឃ្លានយ៉ាងណាស់ហើយ, ប្រសិនបើចំណង់នេះមិនសូវស្ងាត់បាត់ទៅដោយឆាប់រហ័សទេ ខ្ញុំថប់ណាស់ក្រែងតែបណ្ដាលទៅឈឺខ្លាំងម្ដងទៀត" ។ ទូលបង្គំតបភ្លាមថា "មិនអីទេអូន! កុំព្រួយឲ្យសោះ បងនឹងខំស្វះស្វែងរកដើម្បីយកមកបំពេញចិត្តអូនឲ្យបានតែបាន" ។

